00649327

E50/3

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 07 / 03 / 2011
ម៉ោង (Time/Heure): 15 : 40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសង

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣ ខែមិនា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេច**

**លើសំណើសុំឲ្យដោះលែងជាបន្ទាន់**

---

__ដាក់ដោយ៖__

**សហមេធាវីការពារក្ដីលោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGES

លោក Philippe GRECIANO

__នៅចំពោះមុខ៖__

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ អូត្តារ៉ា

__ផ្ញើជូន៖__

**អង្គជំនុំជម្រះតុលាការកំពូល**

ចៅក្រម គង់ ស្រីម

ចៅក្រម Motoo NOGUCHI

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម ស៊ិន វិទ្ធ

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម យ៉ា ណារិន

Original French: 00634825-00634829

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

## សូមគោរពអង្គជំនុំជម្រះតុលាការកំពូល

១. កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ លោក ខៀវ សំផន បានស្នើសុំដោះលែងរូបលោក ("សំណើសុំ") ដោយអនុលោមតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង")។[1]

២. តាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលនូវសំណើសុំនោះ ("ដីកាសម្រេច")។[2]

៣. លោក ខៀវ សំផន សូមដាក់បណ្តឹងឧទ្ធរណ៍នេះ ដោយយោងតាមមាត្រា ៣៦ នៃច្បាប់បង្កើត អ.វ.ត.ក និងវិធាន១០៤ ខ) ១០៥ ២) ១០៦ ២) ៣) ៤) និង១០៧ ២) នៃវិធានផ្ទៃក្នុង។[3]

៤. អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បាន "ភ័ន្តច្រឡំច្បាប់" (erreurs de droit) ព្រោះមិនបានផ្តល់សុពលភាពដល់សេចក្តីសម្រេចរបស់ខ្លួន ព្រមទាំងកំហុសយ៉ាងជាក់ស្តែងក្នុងការវាយតម្លៃ ដែលបង្កឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ដល់ដើមបណ្តឹងឧទ្ធរណ៍។

## ១. ការបកស្រាយដោយភ័ន្តច្រឡំលើវិធាន ៦៨ (៣)

៥. អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃថា ការរក្សាលោក ខៀវ សំផន ឲ្យនៅក្នុងឃុំ ផ្អែកទៅលើមូលដ្ឋានច្បាប់ត្រឹមត្រូវ។[4] អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ដើមបណ្តឹងឧទ្ធរណ៍ "បកស្រាយដោយភ័ន្តច្រឡំ" លើវិធាន ៦៨ (៣) ដែលថាថិរវេលា ៤ ខែដែលបានចែងក្នុងបទប្បញ្ញត្តិនេះចាប់ផ្តើមគិត តាំងពីពេលដែលអង្គជំនុំជម្រះទទួលសំណុំរឿងមកជាផ្លូវការមក។

[1] សំណើសុំដោះលែងឱ្យមានសេរីភាព យោងតាមវិធាន ៨២ (៣) នៃវិធានផ្ទៃក្នុង ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ឯកសារលេខ E18 ("សំណើសុំ")។

[2] ដីកាសម្រេចពាក់ព័ន្ធនឹងសំណើសុំឱ្យដោះលែងជាបន្ទាន់ នួន ជា ខៀវសំផន និង អៀង ធីរិទ្ធ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារតុលាការ E50 ("សេចក្តីសម្រេច")។

[3] ដោយអនុវត្តតាម វិធាន១០៤. ខ ថ្ងៃទី១៦ ខែកញ្ញា ឯកសារតុលាការ ឆ្នាំ២០១០ D427, កថាខណ្ឌ១៦១៣។

[4] ដីកាសម្រេច កថាខណ្ឌទី៤៣ ទំព័រ១៨-១៩

៦. តាមពិតទៅ អង្គជំនុំជម្រះមានចេតនាបំភ័ន្តពាក្យពេចន៍របស់ លោក ខៀវ សំផន ហើយមាក់ងាយលើគោលការណ៍គតិយុត្តិសម្រាប់អនុវត្តទៀតផង។

៧. ផ្ទុយពីការលើកឡើងរបស់អង្គជំនុំជម្រះ[5] ដើមបណ្តឹងឧទ្ធរណ៍មិនធ្លាប់ដែលបានអះអាងថា វិធាន ៦៨ (៣) ត្រូវ "អានជាមួយនឹងមាត្រា៣០៥ និង២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ" ហើយការយោងទៅរកបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានលក្ខណៈចាំបាច់ឡើយ។ ដើម្បីយល់ឲ្យបានច្បាស់ គ្រាន់តែអានសំណើសុំដោះលែង និងរបាយការណ៍សវនាការឲ្យបានត្រឹមត្រូវ និងពេញលេញ នោះជាការស្រេច។[6]

៨. ជំហររបស់លោក ខៀវ សំផន គឺច្បាស់លាស់ ៖ ក) វិធាន ៦៨ (៣) មានលក្ខណៈច្បាស់លាស់៖ ចំណុចចាប់ផ្តើមនៃថិរវេលាកំណត់គឺការជូនដំណឹងពីដីកាដំណោះស្រាយ។ ខ) ការបកស្រាយនេះត្រូវបានពង្រឹងបន្ថែមតាមការអានបទប្បញ្ញត្តិសមស្របនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយដែលសហព្រះរាជអាជ្ញាក៏យល់ស្របតាមដែរ។ គ) ប្រសិនបើក្នុងករណីលើកលែងណាមួយ មានមន្ទិលក្នុងការបកស្រាយលើវិធានច្បាប់ ប្រាកដណាស់ភាពមន្ទិលនេះនឹងត្រូវបានបកស្រាយក្នុងន័យជាប្រយោជន៍ដល់ជនជាប់ចោទ។

៩. អង្គជំនុំជម្រះសាលាកំពូលនឹងសម្គាល់ឃើញថា ក្រៅពីបំភ័ន្តពាក្យពេចន៍ដើមបណ្តឹងឧទ្ធរណ៍ ចៅក្រមសាលាដំបូងនៅបានច្រានចោលអំណះអំណាងសំខាន់ៗដែលបានបង្ហាញ ហើយក៏មិនបានផ្តល់មូលហេតុនៃសេចក្តីសន្និដ្ឋានរបស់ខ្លួនដែលពាក់ព័ន្ធនោះដែរ។

១០. អង្គជំនុំជម្រះសាលាដំបូង បានធ្វើមិនដឹងមិនឮពីជំហរនៃសហព្រះរាជអាជ្ញា ដែលធ្លាប់មានពីមុនមក ហើយដែលបានលើកឡើងអំពីចំណុចនេះម្តងទៀតនៅក្នុងសវនាការ ដោយគ្មានបញ្ជាក់មូលហេតុច្បាស់លាស់ ៖ ចំណុចចាប់ផ្តើមនៃថិរវេលាបួនខែ គឺនៅថ្ងៃដែលធ្វើការការជូនដំណឹងអំពីដីកាដំណោះស្រាយ។[7]

---

[5] ដីកាសម្រេច កថាខណ្ឌទី១១ និង៤៣ ទំព័រ៥-១៨

[6] សំណើសុំ កថាខណ្ឌទី១ ដល់ទី២៥ ៖ "ការបកស្រាយនេះ ត្រូវពង្រឹងបន្ថែមដោយមាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា"។ ដើម្បីជាការប្រៀបធៀប និងជាការចង្អុលបង្ហាញ សូមអានមាត្រា ៣០៥ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ សូមអានផងដែរនូវឯកសារប្រតិចារឹក ជាភាសាខ្មែរ នៃសវនាការ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១។ ឯកសារលេខ E1/1.1, 00642442 ទំព័រ២៨ បន្ទាត់ទី១៥ ដល់ទី១៨។

[7] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងការស្នើសុំដោះលែងលោក នួន ជា ឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ C65/2 កថាខណ្ឌទី១១។ ឯកសារដើមលើកឡើងយ៉ាងច្បាស់ថា ៖ « វិធាននេះ

១១. លើសពីនោះទៀត អង្គជំនុំជម្រះសាលាដំបូងបានធ្វើមិនដឹងមិនឮសោះ ចំពោះសិទ្ធិទទួលបានសុវត្ថិភាពគតិយុត្តិ ដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង[8] តាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងថា ត្រូវបកស្រាយវិធានយ៉ាងណា ដើម្បីការពារប្រយោជន៍របស់ដើមបណ្តឹងឧទ្ធរណ៍ជានិច្ច។

១២. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះ បានមាក់ងាយដល់គោលការណ៍គតិយុត្តិសម្រាប់អនុវត្ត។ អង្គជំនុំជម្រះ បាន“ភ័ន្តច្រឡំច្បាប់” (erreurs de droit) ព្រោះបានវាយតម្លៃថា ការពន្យារការឃុំខ្លួនដោយសហចៅក្រមស៊ើបអង្កេត ស្របតាមវិធាន ៦៨ (៣) មានថិរវេលាបួនខែគិតចាប់ពីថ្ងៃដែលសំណុំរឿងត្រូវបានបញ្ជូនទៅជម្រះ។ ការបកស្រាយរបស់អង្គជំនុំជម្រះពុំមានផ្អែកទៅលើមូលដ្ឋានគតិយុត្តិឡើយ។

១៣. តាមពិតទៅ វិធាន ៦៨ (៣) មានភាពស្រពិចស្រពិល ៖ “<u>ក្នុងករណីណាក៏ដោយ</u> សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំបណ្តោះអាសន្ន (...)តាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ត្រូវអស់អានុភាពក្នុងរយៈពេល៤(បួន)ខែក្រោយលើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួន ទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ”។

---

(វិធាន ៦៨) ចែងថា ការចេញដីកាដំណោះស្រាយមានអានុភាព “បញ្ចប់” ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នពីមុននេះ ក៏ប៉ុន្តែអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងដីកាដំណោះស្រាយ “រក្សាទុកជនជាប់ចោទក្នុងការឃុំខ្លួនបណ្តោះអាសន្នដដែល” សម្រាប់រយៈពេល ៤ ខែ។ រយៈពេលនៃការឃុំខ្លួន៤ខែនេះ<u>គឺដូចគ្នា</u>នឹងរយៈពេលដែលចែងសម្រាប់អង្គបុរេជំនុំជម្រះ ក្នុងវិធាន៦៨-២ ដើម្បីឱ្យធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ណាមួយ ចំះពោះដីកាដំណោះស្រាយ និងមានបំណង<u>យ៉ាងច្បាស់</u>ក្នុងការផ្តល់យៈពេលនៃការឃុំខ្លួនបន្ថែម បន្ទាប់ពីការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអនុញ្ញាតនូវពេលវេលាគ្រប់គ្រាន់សម្រាប់ឱ្យដោះស្រាយលើបណ្តឹងឧទ្ធរណ៍ និងសម្រាប់ឱ្យធ្វើការនាំខ្លួនជនជាប់ចោទទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ វិធាន ៦៨-៣ ចែងយ៉ាងច្បាស់ថា ដីកាសម្រេចណាមួយដូចនេះដោយសហចៅក្រមស៊ើបអង្កេតក្នុងដីកាដំណោះស្រាយ ដើម្បីឃុំខ្លួនជនជាប់ចោទ “ត្រូវអស់អានុភាពក្នុរយៈពេល ៤ ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអម្លុងពេលនោះ។ (ក្នុងឯកសារដើម មិនមានគូសបន្ទាត់ពីក្រោមទេ) ».

[8] ការស្នើសុំ កថាខណ្ឌទី២១ ។ ឯកសារប្រតិចារឹកក្នុងពេលសវនាការ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។ ការស្នើសុំដោះលែងលោក នួន ជា លោក ខៀវ និង អៀង ធីរីទ្ធ ឱ្យមានសេរីភាពឡើងវិញ ឯកសារលេខ E1/1.1

00649332



១៤. វិធាន ៦៨ មិនមានចែងការបញ្ជូនសំណុំរឿងទៅជម្រះនៅអង្គជំនុំជម្រះសាលាដំបូងសោះឡើយ ហើយរឹតតែមិនលើកឡើងពីថិរវេលាបួនខែនោះទៅទៀត។ វិធានផ្ទៃក្នុងគ្រាន់តែបញ្ជាក់ថា ជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងមុនថិរវេលាកំណត់ប៉ុណ្ណោះ។

១៥. ដូច្នោះ ចំណុចចាប់ផ្ដើមនៃថិរវេលាបួនខែ គឺនៅពេលជូនដំណឹងអំពីដីកាដំណោះស្រាយ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ពុំមែននៅថ្ងៃបញ្ជូនសំណុំរឿងទៅជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ នោះឡើយ។ ដូច្នេះ ថិរវេលាត្រូវផុតកំណត់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១១ ម្ល៉ោះ ក្នុងករណីដែលអង្គជំនុំជម្រះមិនបានបង្គាប់ឱ្យនាំខ្លួន លោក ខៀវ សំផន ទៅចំពោះមុខខ្លួន ដែលជាក់ស្ដែងមិនបានធ្វើមែន ដោយសារតែការមិនផ្ចិតផ្ចង់ក្នុងការងាររបស់ខ្លួននេះ។ ឥឡូវនេះ អង្គជំនុំជម្រះអាចមិនសម្រេចសេចក្ដី ដើម្បីបញ្ជាក់ហេតុផលនៃការបន្តឃុំខ្លួនដោយបំពានរបស់ខ្លួន ដោយលើកឡើងថា ជាការបកស្រាយខុសរបស់ដើមបណ្ដឹងឧទ្ធរណ៍លើវិធាន៦៨ (៣) បានឡើយ។

១៦. “ការភ័ន្តច្រឡំច្បាប់” (erreurs de droit) របស់អង្គជំនុំជម្រះសាលាដំបូង មានលក្ខណៈជាក់ស្ដែង ហើយវានាំឱ្យបាត់សុពលភាពដល់សេចក្ដីសម្រេចរបស់ខ្លួន ៖ ដោយខ្វះនូវមូលដ្ឋានច្បាប់ មិនត្រូវបន្តឃុំខ្លួនដើមបណ្ដឹងឧទ្ធរណ៍ទៀតឡើយ។

## ២. ការពន្យល់ហេតុផលដោយភ័ន្តច្រឡំអំពីការរក្សាឃុំខ្លួន

១៧. បន្ទាប់ពីពិនិត្យមើលស្ថានភាពដើមបណ្ដឹងឧទ្ធរណ៍ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា "ខៀវ សំផន អាចនឹងប្រឈមនឹងការផ្ដន្ទាទោសទោសធ្ងន់ធ្ងរ ប្រសិនបើតុលាការរកឃើញថា គាត់មានពិរុទ្ធ នោះ ខៀវ សំផន អាចមានចេតនាកាន់តែខ្លាំងក្នុងការរត់គេចខ្លួន។ ការបន្តដាក់គាត់នៅក្នុងមន្ទីរឃុំឃាំង គឺជាការចាំបាច់ ដើម្បីធានាថាគាត់នឹងមានវត្តមាននៅគ្រប់ដំណាក់កាលនៃសវនាការ”។[9] អង្គជំនុំជម្រះសាលាដំបូងបានបោះបង់ចោលមូលហេតុក្នុងការបន្តឃុំខ្លួន ដែលសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះធ្លាប់បានលើកឡើងពីមុនមក ហើយបានច្រានចោលអំណះអំណាងផ្សេងទៀតរបស់សហព្រះរាជ

[9] ដីកាសម្រេច កថាខណ្ឌទី៤០ ទំព័រ ១៧

អាជ្ញា។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងក៏បានបង្គាប់ឱ្យបន្តឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ ដោយយកតែវិធាន ៦៨ (៣) ខ (៣) នៃវិធានផ្ទៃក្នុង មកអនុវត្តប៉ុណ្ណោះ។

១៨. ធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូងបាន“ភ័ន្តច្រឡំច្បាប់” (erreurs de droit) គឺជាការមាក់ងាយយ៉ាងជាក់ស្តែងទៅលើគោលការការណ៍ច្បាប់អនុវត្តន៍ ក្នុងការអនុវត្តអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន។

១៩. តាមពិតទៅ ជាពិសេសនៅចំពោះមុខគោលការណ៍សន្មតថា គ្មានទោស ទំងន់នៃទោសទណ្ឌ មិនគ្រប់គ្រាន់ទេសម្រាប់យកមកធ្វើជាមូលហេតុក្នុងការបដិសេធដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ក៏ដូចជាការពន្យារការឃុំខ្លួនមុនពេលបើកការជម្រះក្តីឡើយ។[10] យុត្តិសាស្ត្រអន្តរជាតិនៅរក្សាគោលការណ៍នេះដដែល។

២០. សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសអតីតយូហ្គោស្លាវី (“TPIY”) រំឭកថា “អង្គជំនុំជម្រះសាលាដំបូងគប្បីគិតទៅដល់ទម្ងន់នៃបទល្មើសដែលបានចោទប្រកាន់ដើម្បីកំណត់ថា តើទស្សនវិស័យក្នុងការដាក់ទោសធ្ងន់ធ្ងរអាចនឹងជម្រុញឱ្យជនជាប់ចោទរត់គេចទៅថ្ងៃខាងមុខឬយ៉ាងណា" ប៉ុន្តែ "ការចោទប្រកាន់ធ្ងន់ធ្ងរមិនអាចជាចំណុចតែមួយគត់ដែលឱ្យគេសម្រេចលើការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នឡើយ”។ សាលាឧទ្ធរណ៍នេះបានបញ្ជាក់ថា “អង្គជំនុំជម្រះសាលាដំបូងមួយត្រូវគិតទៅដល់ទម្ងន់នៃបទចោទ បន្ថែមពីលើចំណុចជាច្រើនទៀត” (មានគូសបន្ទាត់ពីក្រោមក្នុងអត្ថបទដើម)។[11]

២១. ដោយយកលំនាំដោយផ្ទាល់តាមតុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការ TPIY បានវិនិច្ឆ័យថា “មិនអាចលើកយកអំណះអំណាងពីទម្ងន់នៃទោសទាំងឯកឯងលង់ ដើម្បីប្រឆាំងនឹងជនជាប់ចោទ ក្នុងករណីដែលជនជាប់ចោទគ្រប់រូបត្រូវបានចោទប្រកាន់ចំពោះមុខតុលាការ

---

[10] សូមអាន TPIY ៖ រដ្ឋអាជ្ញា *c. Haradinaj et al.*, IT-04-84-PT, សេចក្តីសម្រេចទាក់ទិននឹងការស្នើសុំនៃក្រុមមេធាវីការពារក្តី ដែលមានបំណងពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃការដោះលែងឱ្យមានសេរីភាពបណ្តោះអាសន្នឡើងវិញចំពោះលោក Ramush Haradinaj នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ / ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ ទំព័រ៦។

[11] TPIY : *Le Procureur c. Cermak et Markac*, IT-03-73-AR65.1, Décision relative à l'appel interlocutoire interjeté contre la décision de la Chambre de première instance de refuser la mise en liberté provisoire, 2 décembre 2004, par. 25-26 (notes de bas de pages omises) ; Voir également, entre autres : *Le Procureur c. Tolimir et al.*, IT-04-80-AR65.1, Décision relative à l'appel interlocutoire interjeté contre des décisions portant mise en liberté provisoire rendues par la Chambre de première instance, 19 octobre 2005, par. 25 ; *Le Procureur c. Popovic et al.*, IT-05-88-AR65.1, Decision on Interlocutory Appeal of Trial Chamber Decision denying Drago Nikolic's Motion for Provisional Release, 24 janvier 2006, p. 5.

ត្រូវទទួលទោសធ្ងន់ធ្ងរប្រសិនបើជនទាំងនោះត្រូវគេទទួលស្គាល់ថាជាពិរុទ្ធជនឡើយ"។[12]

២២. ជនជាប់ចោទគ្រប់រូបដែលត្រូវចោទប្រកាន់ចំពោះមុខ អ.វ.ត.ក "ទទួលទោសធ្ងន់ ប្រសិនបើជនទាំងនោះត្រូវគេទទួលស្គាល់ថា ជាពិរុទ្ធជន"។

២៣. ការដែលអះអាងពីការរក្សាការឃុំខ្លួន លោក ខៀវ សំផន ដោយផ្អែកតែទៅលើទម្ងន់ទោសដែលត្រូវទទួលរង អង្គជំនុំជម្រះសាលាដំបូងបានមាក់ងាយយ៉ាងច្បាស់ក្រឡែតដល់គោលការណ៍ច្បាប់អនុវត្ត។ កំហុសរបស់អង្គជំនុំជម្រះនេះនាំឲ្យបាត់សុពលភាពដល់សេចក្ដីសម្រេច ៖ ក្នុងករណីដែលការផ្ដល់មូលហេតុលើការឃុំខ្លួន ពុំមានបញ្ជាក់ដោយលក្ខណៈវិនិច្ឆ័យផ្សេងក្រៅពីពាក្យពេចន៍ដែលមានចែងតែនៅក្នុង វិធាន ៦៨ (៣) ខ (៣) នៃវិធានផ្ទៃក្នុង ត្រូវតែដោះលែងដើមបណ្ដឹងឧទ្ធរណ៍ឲ្យមានសេរីភាព។

## គ. ការបំពានលើសិទ្ធិទទួលបានការកាត់សេចក្ដីប្រកបដោយយុត្តិធម៌

២៤. ការចេញសេចក្ដីសម្រេចនេះ គឺអង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តនូវកំហុសដ៏ធ្ងន់ធ្ងរ ដែលនាំឲ្យប៉ះពាល់ដល់សមភាពនៃការកាត់សេចក្ដី មិនអាចត្រឡប់ក្រោយវិញបានឡើយ។

## ក. ការបំពានលើសិទ្ធិទទួលបានពេលចាំបាច់ក្នុងការត្រៀមការពារខ្លួន

២៥. ចៅក្រមបានអញ្ជើញគ្រប់ភាគី ដើម្បីលើកឡើងពីលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ៦៨ (៣) នៃវិធានផ្ទៃក្នុង "នៅក្នុងពេលសវនាការ" បើទោះជាសំណើសុំដោះលែងរបស់ក្រុមមេធាវីការពារក្ដី មិនបានឈរនៅលើមូលដ្ឋានគតិយុត្តិនោះឡើយក៏ដោយ។[13] ធ្វើបែបនេះ អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសដ៏ជាក់ច្បាស់ក្នុងការវាយតម្លៃទៅលើអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ដែលនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ដើមបណ្ដឹងឧទ្ធរណ៍។

---

[12] TPIY ៖ រដ្ឋអាជ្ញា *c. Haradinaj et al.*, IT-04-84-PT, ដីកាសម្រេចទាក់ទិននឹងការស្នើសុំនៃក្រុមមេធាវីការពារក្ដីដែលមានបំណងពិនិត្យឡើងវិញនូវលក្ខខណ្ឌនៃការដោះលែងឲ្យមានសេរីភាពបណ្ដោះអាសន្នឡើងវិញចំពោះលោក Ramush Haradinaj នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៥ កថាខណ្ឌទី២៤ និងកំណត់ជើងទំព័រនៃទំព័រ៤៧ ៤៨ និង៤៩។

[13] ដីកាសម្រេច កថាខណ្ឌទី៦ ទំព័រ៣

២៦. តាមពិត ដើមបណ្តឹងឧទ្ធរណ៍មិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ត្រៀមការពារខ្លួនឡើយ ដែលនេះជាសិទ្ធិមួយក្នុងចំណោមសិទ្ធិមូលដ្ឋានទាំងឡាយ។[14] យ៉ាងហោចណាស់ ប្រសិនបើអង្គជំនុំជម្រះបានផ្តល់ព័ត៌មានដល់ក្រុមមេធាវីការពារក្តីថា បញ្ហានេះត្រូវលើកយកទៅនិយាយនៅក្នុងសវនាការ ក្រុមមេធាវីការពារក្តីអាចនឹងពង្រឹង និងពង្រីកអំណះអំណាងដែលបង្ហាញនោះបានច្រើនជាងនោះពុំខាន។

២៧. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា ភាគីទាំងអស់មិនមានពេលគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំអំណះអំណាងឡើយ។ក៏ប៉ុន្តែ លទ្ធភាពក្នុងការ "ជួសជុល" ព្យសនកម្មដែលអង្គជំនុំជម្រះផ្តល់ឱ្យនោះមិនគ្រប់គ្រាន់ទេ។[15] ពីព្រោះថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនទាមទារឱ្យក្រុមមេធាវីការពារក្តីបង្ហាញពីការប្រែប្រួលស្ថានភាព ក្នុងករណីដែលក្រុមមេធាវីការពារក្តីធ្វើសំណើសុំថ្មីឱ្យដោះលែង នៅចំពោះមុខខ្លួនទៀតនោះ។ លក្ខណៈបត់បែនមិនច្បាស់លាស់នៃវិធាន ៨២ (៤) នេះមិនអាចយកទៅថ្លឹងថ្លែងឱ្យបានច្បាស់លាស់ជាមួយនឹងការដោះលែងដើមបណ្តឹងឧទ្ធរណ៍ឱ្យមានសេរីភាពនោះឡើយ។

២៨. ព្យសនកម្មដែលលោក ខៀវ សំផន ទទួលរង វាកាន់តែធ្ងន់ធ្ងរទៅទៀត ខណៈដែលអំណះអំណាងដែលលើកឡើងក្រោយសវនាការក្តី ទាំងក្នុងសំណើសុំលើកមុនៗក្តី មិនត្រូវបានចៅក្រមយកទៅពិនិត្យនោះ។

## ខ. កង្វះការពិចារណាលើអំណះអំណាងក្រុមមេធាវីការពារក្តី និងកង្វះការផ្តល់មូលហេតុ

២៩. អង្គជំនុំជម្រះមិនបានផ្តល់មូលហេតុពាក់ព័ន្ធនឹងអំណះអំណាង របស់ដើមបណ្តឹងឧទ្ធរណ៍ជាពិសេសអំពីការត្រួតពិនិត្យតុលាការ ហើយមិនបានអារកាត់ជាទូទៅលើចំណុចនេះទេ ទោះបីជាត្រូវបានតម្រូវឱ្យធ្វើក៏ដោយ។ ដូច្នេះ អង្គជំនុំជម្រះបាន "ភ័ន្តច្រឡំច្បាប់" (erreurs de droit) ត្រង់ចំណុចពីរយ៉ាង។

---

[14] មាត្រា១៤.៣ ខ នៃកតិកាសញ្ញាអន្តរជាតិទាក់ទិននឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១៣.១ នៃកិច្ចព្រមព្រៀង មាត្រា៣៥ (ថ្មី) នៃច្បាប់បង្កើត អ.វ.ត.ក មាត្រា៦នៃអនុសញ្ញាអឺរ៉ុបដើម្បីរក្សាសិទ្ធិមនុស្ស និងសិទ្ធិមូលដ្ឋាន។

[15] ដីកាសម្រេច កថាខណ្ឌទី៤២ ទំព័រ ១៨

៣០. ម៉្យាង អង្គជំនុំជម្រះបានបន្ទោសជនជាប់ចោទថា "ពុំមានព័ត៌មានលម្អិតទាក់ទងនឹងជម្រើសផ្សេងៗទៀត ជំនួសឲ្យការបង្ហាញខ្លួននៅពេលសវនាការ"។[16] ការបន្ទោសនេះពិតជាមិនផ្អែកលើមូលដ្ឋានច្បាស់លាស់ឡើយ ដោយសារតែអង្គជំនុំជម្រះបានលើកឡើងថា ដើមបណ្តឹងឧទ្ធរណ៍បានគាំទ្រគំនិតដែលថា មាន "វិធានការដទៃទៀតដែលផ្តល់លក្ខខណ្ឌសុវត្ថិភាពគ្រប់គ្រាន់"។[17]

៣១. លើសពីនោះទៅទៀត នៅក្នុងសវនាការ និងទាំងក្នុងសំណើសុំឲ្យដោះលែងកន្លងមក[18] ដើមបណ្តឹងឧទ្ធរណ៍បានគាំទ្រជាច្រើនដងដល់អំណះអំណាងទាំងនេះ មិនចាំបាច់នាំចៅក្រមពិបាកក្នុងការពន្យល់ពីការវិភាគរបស់ខ្លួនលើចំណុចនេះនោះឡើយ។

៣២. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុស ដោយមិនបានផ្តល់នូវសារសំខាន់ដល់អំណះអំណាងសំខាន់ៗរបស់ លោក ខៀវ សំផន និងដោយមិនបានផ្តល់មូលហេតុក្នុងសេចក្តីសន្និដ្ឋានដែលពាក់ព័ន្ធ។

៣៣. ម៉្យាងទៀត អង្គជំនុំជម្រះបានទទួលស្គាល់ពីយុត្តាធិការរបស់ខ្លួន តាមវិធាន ៨២ (២) នៃវិធានផ្ទៃក្នុង ដែលចែងថាអង្គជំនុំជម្រះ "អាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬដាក់ឲ្យត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទ ស្របតាមវិធានផ្ទៃក្នុងនេះ"។[19]

៣៤. ក៏ប៉ុន្តែ វិធាននេះតម្រូវឲ្យអង្គជំនុំជម្រះត្រូវមានកាតព្វកិច្ចសម្រេចលើការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយសារការឃុំខ្លួនគឺជាអញ្ញត្រកម្ម (បន្ទាប់ពីការបាត់បង់សេរីភាពអស់ជាច្រើនឆ្នាំ)។ ក្នុងករណីពិសេសនេះ គេសង្កេតឃើញយ៉ាងច្បាស់ថា ចៅក្រមបានលាក់បំបាំងទាំងស្រុងនូវលទ្ធភាពក្នុងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

---

[16] ដីកាសម្រេច កថាខណ្ឌទី៣៩ ដល់ទី៤១ ទំព័រ១៦-១៨

[17] ដីកាសម្រេច កថាខណ្ឌទី៣៩ ដល់ទី៤១ ទំព័រ១៦-១៨

[18] ឯកសារប្រតិចារឹកនៃសវនាការ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ការស្នើសុំដោះលែងលោក នួន ជា លោក ខៀវ សំផន លោកស្រី អៀង ធីរិទ្ធ ឲ្យមានសេរីភាព ឯកសារសាធារណៈលេខ n° E1/1.1, 00642848, ទំព័រ៧៩ បន្ទាត់១៦ និង 00642850 និង 00642851 ទំព័រ៨១ បន្ទាត់២៥ និងទំព័រ៨២ បន្ទាត់១ សូមអានឧទាហរណ៍ដូចជា ការជំទាស់របស់របស់ក្រុមមេធាវីការពារក្តី ទាក់ទិននឹងការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន។

[19] ដីកាសម្រេច កថាខណ្ឌទី២១ ទំព័រ៩ (នៅក្នុងឯកសារដើម មិនមានគូសបន្ទាត់ទេ)

00649337



៣៥. ដូចតុលាការកំពូលរបស់បារាំងដែរ[20] តុលាការកំពូលរបស់កម្ពុជានឹងបដិសេធសេចក្ដីសម្រេចរបស់ចៅក្រមថ្នាក់ក្រោម ដែលពន្យារការឃុំខ្លួនបណ្ដោះអាសន្ន ដោយឥតបញ្ជាក់ថា ហេតុដូចម្ដេចបានជាការត្រួតពិនិត្យតុលាការគ្មានការធានាគ្រប់គ្រាន់នោះឡើយ ហើយដោយឥតផ្ដល់មូលហេតុចំពោះការសម្រេចសេចក្ដីរបស់ខ្លួនឡើយ។

៣៦. ដូចសាលាឧទ្ធរណ៍នៃ TPIY បានរំលឹកដូច្នេះដែរ អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែត្រូវពិចារណាលើរាល់កត្តាសមស្របទាំងអស់ ដែលអង្គជំនុំជម្រះត្រឹមត្រូវមួយអាចនឹងពិនិត្យ មុននឹងសម្រេចសេចក្ដីលើការដោះលែងជាបណ្ដោះអាសន្នជនជាប់ចោទណាម្នាក់ប៉ុណ្ណោះទេ តែអង្គជំនុំជម្រះត្រូវតែផ្ដល់នូវមតិវិភាគត្រឹមត្រូវមួយ ដោយមានចង្អុលបង្ហាញពីយោបល់របស់ខ្លួន នៅលើកត្តាសមស្របទាំងនោះ និងសារសំខាន់អមជាមួយយោបល់ទាំងនោះ។ [21]

៣៧. ដូច្នេះហើយ យុត្តិធម៌អន្តរជាតិដែលមានគុណសម្បត្តិយល់ដឹងដោយទាមទារលក្ខខណ្ឌច្បាប់ ដើម្បីឲ្យដោះលែងជនជាប់ចោទបាន ដោយមិនធ្វើឲ្យខូចប្រយោជន៍ក្នុងការបើកសវនាការនៅក្នុងរឿងក្ដីនេះ។

៣៨. សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវគ្មានសុពលភាព ដោយមាន "ការភ័ន្តច្រឡំច្បាប់" (erreurs de droit) ៖ ការរក្សាទុកដើមបណ្ដឹងឧទ្ធរណ៍នៅក្នុងមន្ទីរឃុំឃាំងមិនមានមូលហេតុត្រឹមត្រូវ បង្ហាញអំពីកង្វះការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលធានាបានដូចគ្នាឲ្យកូនក្ដីយើងខ្ញុំអាចចូលមកកាន់តុលាការបាន (វិធាន៦៣.៣ ខ.៣)។

៣៩. រួមសេចក្ដីមក កំហុសដែលប្រព្រឹត្តឡើងដោយអង្គជំនុំជម្រះ ទោះជារួមគ្នាក្ដី ឬដោយឡែកពីគ្នាក្ដី គឺជាការប្រកែកមិនព្រមផ្ដល់យុត្តិធម៌ ហើយធ្វើឲ្យបាត់បង់សុពលភាពលើដីសេចក្ដីសម្រេច។ លោក ខៀវ សំផន ត្រូវតែទទួលបាននូវការដោះលែងឲ្យមានសេរីភាព។

---

[20] តុលាការកំពូល សាលាឧក្រិដ្ឋ n°97-83.014 ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៧

[21] TPIY : *រដ្ឋអាជ្ញា c. Popovic et al.*, IT-05-88-AR65.3, Decision on Interlocutory Appeal of Trial Chamber's Decision denying Ljubomir Bovcanin Provisional Release, ថ្ងៃទី១ ខែមិនា ឆ្នាំ២០០៧ កថាខណ្ឌ ៧ និង១៣។

## សេចក្តីបញ្ចប់

២៨. ដើមបណ្តឹងឧទ្ធរណ៍សូមឲ្យអង្គជំនុំជម្រះតុលាការកំពូល មេត្តា៖

- បដិសេធសេចក្តីសម្រេច ចំពោះបញ្ញត្តិដែលបានជំទាស់នេះ
- បង្គាប់ឲ្យដោះលែង លោក ខៀវ សំផន ជាបន្ទាន់
- ព្រមទទួលថា លោក ខៀវ សំផន ទទួលរងការរំលោភលើសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ និងមានព្យសនកម្មធ្ងន់ធ្ងរ។

## រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ប៉ារីស | |
| | មេធាវី Philippe GRECIANO | ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |